# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៥១
ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១០
-ជំនុំជម្រះលេខ ១៧២២
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០
-សាលក្រមព្រហ្មទណ្ឌលេខ ១២៨ក្រ១
ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ :

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៥១ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១០ ដែលមាន :

១-ជនជាប់ចោទឈ្មោះ [redacted] **ជាង** ភេទ ស្រី អាយុ ៤០ឆ្នាំ ជាតិ ខ្មែរ សាសនា ព្រះពុទ្ធ កើតនៅភូមិរាំងខាងត្បូង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះ [redacted]សង្កាត់បឹងកង់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរ លក់ត្រី ប្ដីឈ្មោះ [redacted] "រ" មានកូន ០៤នាក់ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" កិរិតវប្បធម៌ អត់ចេះអក្សរ ទោសពីមុន គ្មាន

ឃាត់ខ្លួនថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៩៧ ត.ព្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ ។

-លោក[redacted]សុត្ថា ជាមេធាវីការពារជនជាប់ចោទ

២-ជនជាប់ចោទឈ្មោះ [redacted] **ចឹហៀង** ភេទ ស្រី អាយុ ៤៨ឆ្នាំ ជនជាតិ វៀតណាម សញ្ជាតិ វៀតណាម សាសនា ព្រះពុទ្ធ កើតនៅប្រទេសវៀតណាម ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ [redacted]ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរ កោសខ្យល់ ប្ដីឈ្មោះ [redacted] "ស" មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" កិរិតវប្បធម៌ ថ្នាក់ទី៣ ទោសពីមុន គ្មាន

ឃាត់ខ្លួនថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៩៩ ត.ព្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ ។

-លោក [redacted]ក្រា ជាមេធាវីការពារជនជាប់ចោទ

-លោក [redacted]កៅ ជាអ្នកបកប្រែភាសាវៀតណាម

៣-ជនជាប់ចោទឈ្មោះ [redacted] ធី ភេទ ស្រី អាយុ ៤៣ឆ្នាំ ជាតិ ខ្មែរ សាសនា ព្រះពុទ្ធ កើតនៅភូមិពាលញ្ញែក ឃុំពាលញ្ញែក ស្រុកបាកាន ខេត្តពោធិ៍សាត់ ទីលំនៅមុនពេលឃាត់ខ្លួន[redacted] ខណ្ឌ៧មករា រាជធានីភ្នំពេញ មុខរបរ នៅផ្ទះ ប្ដីឈ្មោះ [redacted] "លែងលះ" មានកូន ០៣នាក់ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "ស" កំរិតវប្បធម៌ ថ្នាក់ទី៩ ទោសពីមុន គ្មាន

ឃាត់ខ្លួនថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣០០ ត.ព្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ ។

-លោក [redacted]ណាល់ ជាមេធាវីការពារជនជាប់ចោទ

៤-ជនជាប់ចោទឈ្មោះ [redacted] អេះ ភេទ ស្រី អាយុ ៥៩ឆ្នាំ ជាតិ ខ្មែរ សាសនា ព្រះពុទ្ធ កើតនៅស្រុកព្រែកជ្រូក ប្រទេសវៀតណាម ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះ [redacted] សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរ លក់ផ្លែដូងខ្ចី ប្ដីឈ្មោះ [redacted] "រ" មានកូន ០៥នាក់ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" កំរិតវប្បធម៌ មិនចេះអក្សរ ទោសពីមុន គ្មាន

ឃាត់ខ្លួនថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣០១ ត.ព្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ ។

-លោក [redacted]ក្រា ជាមេធាវីការពារជនជាប់ចោទ

៥-ជនជាប់ចោទឈ្មោះ [redacted]ពៅ ភេទ ស្រី អាយុ ៥១ឆ្នាំ ជាតិ ខ្មែរ សាសនា ព្រះពុទ្ធ កើតនៅភូមិជីឃ្មល់ ឃុំគោកព្រិច ស្រុកគីរីវង្ស ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួន[redacted] ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរ តូកជេរជី ប្ដីឈ្មោះ [redacted] "រ" មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ទោសពីមុន គ្មាន

ឃាត់ខ្លួនថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ និងឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៩៨ ត.ព្រ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ ។

-លោក [redacted]សម្បត្តិ ជាមេធាវីការពារជនជាប់ចោទ

ជាប់ចោទពីបទ **អូសទាញពេស្យាចារកុមារ** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ✓



Scanned by CamScanner

-ជនរងគ្រោះឈ្មោះ [redacted] ពៅ ភេទ ស្រី អាយុ ១៤ឆ្នាំ ជាតិ ខ្មែរ សាសនា ព្រះពុទ្ធ កើតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះលេ[redacted]សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ មុខរបរ សិស្ស នៅលើវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ[redacted] ។

-ជនរងគ្រោះឈ្មោះ [redacted]ម៉ាយ ភេទ ស្រី អាយុ ១៥ឆ្នាំ ជនជាតិ វៀតណាម សាសនា ព្រះពុទ្ធ កើតនៅសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះជួល [redacted] សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មុខរបរ នៅផ្ទះ នៅលើវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ។

-**បានឃើញ** របាយការណ៍សំយោគលេខ ០៩៨/១០ រ.ប.ក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ១៧២៨ អ.យ.ញ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១០ របស់លោក[redacted] [redacted]ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ២២១៧ ៥.ជ.រ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ របស់លោកស្រី [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាបង្គាប់ឱ្យនាំជនជាប់ចោទមកសាលាដំបូងរាជធានីភ្នំពេញលេខ ១៧៤៧៤ ត.ព្រ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០ របស់លោក[redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

**អង្គហេតុនៃរឿងមានដូចតទៅ:**

កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចុះអនុវត្តតាមចំណារលេខ ៦៨ អ.យ.ឃ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ របស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ បានចុះបង្ក្រាបករណីជួញដូរមួយនៅរាជធានីភ្នំពេញ ដែលកំពុងអូសទាញជនរងគ្រោះដែលមានឈ្មោះ [redacted]ម៉ាយ និងឈ្មោះ [redacted] ពៅ ដែលជាអនីតិជនអាយុក្រោម ១៨ឆ្នាំទៅធ្វើពេស្យាចារ ហើយកំលាំងសមត្ថកិច្ចបានធ្វើការបង្ក្រាបជាក់ស្តែង និងឃាត់ខ្លួនជនល្មើសចំនួន ៥នាក់ មាន ១-ឈ្មោះ [redacted] ពៅ ២-ឈ្មោះ [redacted]ធី ៣-ឈ្មោះ [redacted] អេះ ៤-ឈ្មោះ [redacted]ផាង និងឈ្មោះ [redacted]ហឿង មកកាន់ការិយាល័យតែម្តង ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted]ផាង បានឆ្លើយថា : ខ្លួនមានមុខរបរជាអ្នកលក់ត្រី និងប្រហិតខ្លួនពុំបានលក់ដូរឈ្មោះ ម៉ាយ ទេ គឺវាជាអ្នកស៊ីឈ្នួលកោសប្រហិតឱ្យខ្លួន ។ ឈ្មោះ ម៉ាយ ភេទ ស្រី ស៊ីឈ្នួលកោសប្រហិតឱ្យខ្លួនប្រហែល១ខែហើយ វាចេះនិយាយភាសាខ្មែរ ប្រាក់ខែវាមួយខែ១២ម៉ឺនរៀល ហើយវាស្នាក់នៅផ្ទះខ្លួនជូនវាទៅផ្ទះវា បើត្រីច្រើនវាពុំអាចទៅផ្ទះវាបានទេ ។ ខ្លួនទើបស្គាល់



Scanned by CamScanner

ម្តាយវាតាមរយៈជួលផ្ទះក្បែរគ្នា ។ ក្រៅពីកោសប្រហិតឈ្មោះ ម៉ាយ ជួយធ្វើការងារផ្ទះដែរ ឈ្មោះ ម៉ាយ ពុំដែលដើរលេងយប់ទេ បើពេលថ្ងៃវាទៅផ្ទះម្តាយវាដែរ ។ រឿងវាមាន ឬគ្មានមិត្តភក្តិខ្លួនពុំដឹងទេព្រោះរវល់លក់រហូត ។ ខ្លួនពុំស្គាល់ឈ្មោះ [redacted]ពៅ ទេ ។ ឈ្មោះ [redacted]ពៅ ក៏ពុំស្គាល់ដែរ ។ ឈ្មោះ[redacted]អេះ ក៏ពុំស្គាល់ដែរ ។ ខ្លួនស្គាល់ឈ្មោះ [redacted]ធី ប្រហែល ២ខែហើយ គាត់ជាម៉ូយត្រីរបស់ខ្លួន ពុំដឹងថា ឈ្មោះនេះមានមុខរបរអ្វីផ្សេងទៀតទេ ។ ឈ្មោះនេះទិញត្រីខ្លួននៅផ្សារ ពុំមែនទិញនៅផ្ទះទេ ។ ឈ្មោះ ម៉ាយ កោសប្រហិតជូននៅផ្សារ ជូននៅផ្ទះ ឯឈ្មោះ[redacted] ធី ពុំដែលជួបឈ្មោះ ម៉ាយ នៅផ្ទះទេ ពុំដែលស្គាល់គ្នាទេ ។ ជីវភាពម្តាយឈ្មោះ ម៉ាយ ខ្លួនពុំដឹងទេ ហើយខ្លួនពុំបានសន្យាថា ជួលឈ្មោះ ម៉ាយ នេះយូរប៉ុណ្ណាទេ ។ ហើយម្តាយឈ្មោះ ម៉ាយ ពុំដែលមកផ្ទះខ្លួនទេ ។ ជូនកាលបាត់ឈ្មោះ ម៉ាយ ១ថ្ងៃដែរ ពេលវាមកវិញវាប្រាប់ថា ទៅផ្ទះម្តាយវា ហើយពេលខ្លះវាបានយកកូនខ្លួនអាយុ ៩ឆ្នាំទៅដែរ ។ គ្មានជនប្លែកៗ ណាមកទាក់ទងជាមួយឈ្មោះ ម៉ាយ ទេ នៅនគរបាលក៏ខ្លួនឆ្លើយដូចពេលនេះដែរ ។ ខ្លួនពុំបានអូសទាញពេស្យាចារកុមារទេ ហើយខ្លួនក៏ពុំដែលនាំគេទៅសណ្ឋាគារដែរ ខ្លួនពុំដែលស្គាល់សណ្ឋាគារផង ។ ផ្ទះខ្លួនមានកូនខ្លួន និងឈ្មោះ ម៉ាយ បីនាក់ខ្លួន ។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ខ្លួនពុំបាននាំឈ្មោះ ម៉ាយ ទៅណាទេ ពេលនោះខ្លួនកំពុងហូបបាយ មានមនុស្សមកប្រាប់ថា កូនខ្លួនមានគ្រោះថ្នាក់ចរាចរណ៍ ខ្លួនចេញមកហើយត្រូវគេនាំមកប៉ុស្តិ៍នគរបាលតែម្តង ។ ខ្លួនពុំទទួលស្គាល់ការចោទប្រកាន់ទេ ។ ខ្លួនពុំបានឆ្លើយថា បាននាំក្មេងទៅខុយក្រមុំទេ ។ ខ្លួនពុំចេះអក្សរ សុំបដិសេធចម្លើយនៅនគរបាលនេះ គេឱ្យផ្តិតមេដៃតែម្តង ដោយពុំបានអានឱ្យស្តាប់ទេ ហើយពេលនោះស្តាប់មិនចូលផង នគរបាលគេសួរខ្ញុំម្នាក់ឯង គ្មានសាក្សីបញ្ជាក់ជូនតុលាការទេ ពេលនោះខ្លួនយំរហូតពុំចាំច្បាស់ពីចម្លើយក្នុងកំណត់ហេតុនោះទេ ។ ម្តាយឈ្មោះ ម៉ាយ ពុំដែលនិយាយជាមួយខ្លួនរឿងខុយក្រមុំអីទេ ។ ខ្លួនបានទទួលឈ្មោះ ម៉ាយ ពីម្តាយវាផ្ទាល់ គាត់ឱ្យវាមកជួយកោសប្រហិតខ្លួន ពុំមានអ្នកផ្សេងមកជាមួយទេ ។ ឈ្មោះ ម៉ាយ ខ្លួនពុំបានសួរអាយុវាទេ ។ ខ្លួនពុំស្គាល់ឈ្មោះ ចូវ ទេ ។ នៅផ្ទះខ្លួនមានកូនខ្លួន និងសិស្សសាលាប្រុសៗ ២នាក់ ។ ឈ្មោះ ដា ជាកូនបង្កើតរបស់ខ្លួន ប្រុសៗ ជាក្មួយបង្កើតរបស់ខ្លួន ។ មុនពេលឃាត់ខ្លួន ខ្លួនពុំបានឱ្យគេនាំឈ្មោះ ម៉ាយ ទៅហាងកាហ្វេទេ ។ ខ្លួនទៅលក់ត្រីប្រហិតតាំងពីម៉ោង ៥ព្រឹករហូតដល់ម៉ោង ១១ ឬ ១២ថ្ងៃ ទើបមកដល់ផ្ទះ ។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ខ្លួនទៅផ្សារតាំងពីម៉ោង ៥ព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់ ។ ខ្លួនស្គាល់ឈ្មោះ ហឿង ប្រហែល ២ខែ ដោយសារជួលផ្ទះជិតគ្នា ។ ខ្លួនឱ្យគាត់រកឈ្នួលឱ្យគាត់ថា ឱ្យកូនគាត់ឈ្មោះ ម៉ាយ មកនៅកោសប្រហិតត្រី ។ ពុំមានឈ្មោះ ចូវ នាំម្តាយកូននេះមកឱ្យរកម៉ូយខុយក្រមុំទេ គ្មានចម្លើយនេះទេ ។ ខ្លួនពុំស្គាល់ឈ្មោះ [redacted] អេះ ទេ ហើយក៏ពុំដែលទិញដូងពីឈ្មោះនេះដែរ ហើយក៏ពុំដែលទៅហាងកាហ្វេមឈ្នួលគីរីអ្វីទាល់តែសោះ ។

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ផាង នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ 𝒴





Scanned by CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ហឿង បានឆ្លើយថា : ខ្លួនមានកូនម្នាក់ឈ្មោះ ម៉ាយ មានអាយុ ១៧ឆ្នាំ ពុំចាំឆ្នាំកើតទេព្រោះខ្លួនឈឺច្រើនពេក ។ ខ្លួនមកស្រុកខ្មែរ ២០ឆ្នាំហើយ ហើយមានប្តីខ្មែរ ប្តីខ្លួនស្លាប់តាំងពីកូននេះអាយុ ២ឆ្នាំ ។ កូនខ្លួនទៅនៅជាមួយឈ្មោះ [redacted]ផាង ដោយសារខ្លួនឈឺបេះដូង សួត ជម្ងឺច្រើនមុខទៀត ដោយទៅនៅបានប្រាក់ខែ ៤០ដុល្លាមួយខែ ។ កូនខ្លួនធ្វើការបានជិត ១ខែ ពុំទាន់បានបើកប្រាក់ខែទេ ។ ក្រៅពីឱ្យទៅនៅជាមួយឈ្មោះ [redacted] ផាង ពុំឱ្យកូនខ្លួនធ្វើអីទៀតទេ ។ ខ្លួនពុំស្គាល់ឈ្មោះ [redacted]ធី ឈ្មោះ [redacted] អេះ ឈ្មោះ [redacted]ពៅ ទេ ។ ទោះបីជាក្រក៏ខ្លួនពុំមានបំណងឱ្យកូនទៅធ្វើការដែរ គឺវាទៅខ្លួនវា ហើយខ្លួនក៏ពុំបានជូនទៅដែរ ខ្លួនឈឺទៅពុំរួចទេ ។ ខ្លួនគ្មានបំណងចង់លក់កូនទេ ។ ខ្លួនពុំបានទាក់ទងជាមួយឈ្មោះ [redacted]ផាង លក់ខ្លួនកូនយកប្រាក់ទេ ។ ពេលកូនទៅនៅជាមួយឈ្មោះ ផាង ពុំដែលមកផ្ទះទេ គឺមកម្តងពេលជិតចូលឆ្នាំចិនយួន ឯខ្លួនក៏ពុំដែលចេញចូលផ្ទះឈ្មោះ ផាង ដែរ ។ ខ្លួនស្គាល់ឈ្មោះ ផាង ព្រោះមានផ្ទះក្បែរផ្ទះខ្លួន ហើយលក់ត្រីនៅផ្សារ ឯខ្លួនមានរបរជាអ្នកស៊ីឈ្នួលគេផង កោសខ្យល់ឱ្យគេផង ។ ពេលចូលឆ្នាំនោះកូនខ្លួនប្រាប់ថា វាខ្ចីប្រាក់ពីថៅកែ ៤០ដុល្លា ពុំមែនខ្លួនខ្ចីប្រាក់ទេ ។ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១០ ខ្លួនដាក់សៀមនៅផ្ទះខ្លួន ពុំបានទៅជួបនរណាម្នាក់ទេ ។ ខ្លួនពុំបាននាំកូនទៅជួបឈ្មោះ ផាង ដើម្បីខុយក្រមុំ ឬរកម៉ូយខុយក្រមុំទេ ។ ខ្លួនត្រូវឃាត់ខ្លួនថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០១០ ខ្លួននៅក្បែរផ្សារដើមគរ ពេលខ្លួនទៅកន្លែងនោះសួររកកូន ដោយឮថា កូនត្រូវគេឃាត់នៅទីនោះ ។ ពេលទៅដល់កន្លែងនគរបាលខ្លួនពុំឃើញឈ្មោះ ផាង នៅទីនោះទេ ប្រហែល ១ម៉ោងទៅ ២ម៉ោងក្រោយមកទើបឃើញឈ្មោះ ផាង ។

-ជនជាប់ចោទឈ្មោះ [redacted] ធី បានឆ្លើយថា : នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១០ ម៉ោង ៩ ខ្លួនទៅញ៉ាំគុយទាវជាមួយឈ្មោះ ចែត ពៅ ហើយបានជួបក្មេងម្នាក់មិនស្គាល់រកការងាររត់តុកាហ្វេធ្វើដោយចៃដន្យ ក៏បានសន្យាថា នឹងជួយរកការងារឱ្យ ។ ឈ្មោះ ផាង ជាម៉ូយត្រី ធ្លាប់មកផ្ទះខ្លួនដែរ ចម្លើយខ្លួននៅនគរបាលដែលថា ឈ្មោះ ផាង ទាក់ទងខ្លួនរកម៉ូយឱ្យក្មេងស្រីអាយុ ១៦ឆ្នាំម្នាក់ពុំត្រឹមត្រូវទេ ។ ក្រោយពេលចេញពីហូបគុយទាវម៉ោង ១១ ចេញទៅហូបបាយជាមួយ [redacted] ពៅ ក្មេងនោះទៅជាមួយខ្លួន និង[redacted] ពៅ ម្តុំឡាក់គីស្តារ ហើយរកការងារឱ្យវាផង ។ នគរបាលឃាត់ខ្លួនតែម្នាក់ឯងនៅក្បែរឡាក់គីស្តារ ព្រោះពេលនោះបែកគ្នា ។ ឈ្មោះ ហឿង និងឈ្មោះ អេះ ខ្លួនពុំស្គាល់ទេ ។ ពេលនោះក្មេងញ៉ាំគុយទាវដែរ ដោយខ្លួនជាអ្នកចេញប្រាក់ ។ ខ្លួនពុំបានជូនក្មេងទៅងូតទឹក ទិញខោអាវ ទៅផ្ទះពេទ្យពិនិត្យឈាមអីទេ ។ ខ្លួនពុំដែលបានទទួលកំរៃពីក្មេងនោះទេ ហើយក៏ពុំបានទាក់ទងជាមួយជនជាតិចិនណាដែរ ។ ដំបូងខ្លួនជួបក្មេងស្រីតែម្នាក់ទេ ក្រោយមកក្មេងស្រីម្នាក់ទៀតមកដែរគឺក្មេងស្រីទាំងពីរនាក់ដែលមានក្នុងសវនាការនេះហើយ ។ ជួបក្មេងវៀតណាមមុន ហើយក្មេងខ្មែរនេះមកក្រោយ ហើយក្មេងទាំងពីរនាក់នេះទើបជួបនៅថ្ងៃនោះពីមុនមកពុំដែលជួបទេ ។ ចម្លើយខ្លួននៅនគរបាលខ្លួនចាំបានខ្លះគឺឆ្លើយថា រកស៊ីជាមួយឈ្មួញតូកជេរជើ ។ ចម្លើយនៅនគរបាលខ្លួនពុំបានឆ្លើយថា នាំក្មេងទៅពិនិត្យឈាម ហើយនាំទៅសណ្ឋាគារនោះទេ ។ ខ្លួនសុំបដិសេធន៍ចម្លើយខ្លួននៅនគរបាលទាំងស្រុង



Scanned by CamScanner

ខ្លួនពុំដែលស្គាល់កន្លែងពេទ្យពិនិត្យក្មេងនោះទេ ។ ខ្លួនត្រូវនគរបាលឃាត់ខ្លួនពេលខ្លួនចុះពីរអាធុក១ ពីរនាក់ឈ្មោះ [redacted] ពៅ គឺឃាត់នៅលើផងផ្លូវពុំមែនក្នុងសណ្ឋាគារទេ ។ ខ្លួនពុំដែលឮឈ្មោះ ផាង និយាយពីរឿងលក់ក្រមុំទេ ។ ពេលចុះពីរអាធុក១ គឺឈ្មោះ [redacted] ពៅ ចុះទៅផ្សេង ខ្លួនចុះទៅផ្សេង ។ ខ្លួនមកឡាក់គីស្តាជាមួយឈ្មោះ [redacted] ពៅ ពុំមែនមកមុនមកក្រោយទេ ។

-ក្រឡាបញ្ជីអានចម្លើយអាចម្លើយជនជាប់ចោទឈ្មោះ [redacted] ធី នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ។

-ជនជាប់ចោទឈ្មោះ [redacted] ពៅ បានឆ្លើយថា : នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ឈ្មោះ [redacted] ធី តែមកខ្លួនទៅឡាក់គីស្តា ខ្លួនមកដល់ឡាក់គីស្តាពុំទាន់បាន ជួបឈ្មោះ [redacted] ធី ផង ក៏ត្រូវនគរបាលឃាត់ខ្លួនតែម្តង ។ ខ្លួនពុំដឹងពីរឿងពិនិត្យព្រហ្មចារីទេ ។ ចម្លើយនៅនគរបាលបានសំឡុតខ្លួនពុំបានឆ្លើយសារភាពនោះទេ តែពុំបានវាយខ្លួនទេ ។ ខ្លួនសុំបដិសេធចម្លើយខ្លួននៅនគរបាលព្រោះខ្លួនពុំបានប្រព្រឹត្តបទល្មើសទេ ។ ខ្លួនពុំបាននាំក្មេងស្រីឱ្យជនជាតិចិនមើលទេ ។ ខ្លួនរកស៊ីតែឌុកជេរជីតែមួយមុខ គ្មាននាំក្មេងស្រីឱ្យគេលក់ក្រមុំទេ ។ នគរបាលឃាត់ខ្លួននៅមុខសណ្ឋាគារឡាក់គីស្តាពុំបានចូលសណ្ឋាគារនោះទេ ពេលឃាត់ខ្លួននគរបាលបានដកហូតទូរស័ព្ទខ្លួនមួយគ្រឿង ។ សៀវភៅកត់លេខទូរស័ព្ទខ្លួនពុំដឹងទេ នៅថ្ងៃឃាត់ខ្លួននោះខ្លួនបានទាក់ទងតែជាមួយឈ្មោះ [redacted] ធី ពុំទាក់ទងជាមួយនរណាផ្សេងនោះទេ ។ ពេលថ្ងៃត្រង់ពុំបានហូបបាយទេ បែកគ្នារៀងខ្លួនញ៉ាំបាយនៅផ្ទះ ។ ថ្ងៃគុយទាវចេញរៀងខ្លួន ។ ខ្លួនពុំបាននាំក្មេងទៅគ្លីនិច ឬទៅពិនិត្យឈាមទេ គ្មានទិញអាវឱ្យក្មេងទេ ហើយក៏គ្មានបានទាក់ទងជាមួយភ្ញៀវបរទេសណានោះទេ ។ ក្នុងចំណោមជនជាប់ចោទទាំងបួននាក់នេះខ្លួនស្គាល់តែឈ្មោះ [redacted] ធី ម្នាក់គត់ ។ ចម្លើយខ្លួននៅនគរបាលបានអានឱ្យស្តាប់ហើយខ្លួនប្រកែកតែនគរបាលឱ្យផ្តិតមេដៃខ្លួនខ្លាចគេវាយផង ។ ចម្លើយនៅអយ្យការ និងនៅចៅក្រមស៊ើបសួរ ក៏ពុំទទួលយកដែរ ខ្លួនទទួលយកតែចម្លើយពេលនេះគត់ ។ ពេលនោះខ្លួនទៅតែជាមួយឈ្មោះ [redacted] ធី ពុំមានក្មេងស្រីណាទៅជាមួយនោះទេ ។ ចម្លើយខ្លួននៅតុលាការពុំមានការបង្ខំចម្លើយទេ ។ ចេញពីហាងកាហ្វេរមណ្ឌលគិរីមកផ្ទះរៀង១ខ្លួន ។ ញ៉ាំគុយទាវជាមួយឈ្មោះ [redacted] ម៉ោងប្រហែល ៩ ទៅ ១០ព្រឹក ហើយបែកគ្នារហូតដល់ម៉ោង ២រសៀល ។ ខ្លួនជិះម៉ូតូឌុបមកឡាក់គីស្តាម្នាក់ឯង ។ ពីមុនមកពុំដែលស្គាល់ក្មេងទាំងពីរនាក់នេះទេ ។ ពុំដែលស្គាល់ឈ្មោះ [redacted] អេះ ទេ ហើយក៏ពុំដែលទៅទិញដូងគាត់ដែរ ។ ឈ្មោះ ហឿង ក៏ពុំស្គាល់ដែរ ។

-ក្រឡាបញ្ជីអានចម្លើយអាចម្លើយជនជាប់ចោទឈ្មោះ [redacted] ធី នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ។

-ជនជាប់ចោទឈ្មោះ [redacted] អេះ បានឆ្លើយថា : ប្តីខ្លួនឈ្មោះ [redacted] បានរៀបការនៅយួន ។ ខ្លួនមានកូន ៥នាក់ ស្រី ២ ប្រុស ៣ ។ ឈ្មោះ [redacted] ពៅ ជាកូនពៅខ្លួនមានអាយុ ១៥ឆ្នាំហើយ ។ ខ្លួនពុំបានយកកូនទៅលក់ឱ្យគេ ឬលក់ក្រមុំកូនឱ្យគេទេ ។ ខ្លួនលក់ដូង ២០ឆ្នាំហើយនៅ

ផ្សារថ្មី ។ ខ្លួនត្រូវនគរបាលឃាត់ខ្លួននៅមុំបារដាក់ដុង ។ ខ្លួនពុំដែលស្គាល់សណ្ឋាគារណាទេ ហើយក៏ពុំដែលស្គាល់នរណាដើម្បីលក់កូនទេ ។ ខ្លួនពុំទទួលយកការចោទប្រកាន់ទេ ហើយក៏ពុំបានដឹងរឿងអ្វីនោះដែរ ។ ខ្លួនពុំស្គាល់ជនជាប់ចោទទាំងបួននាក់នេះទេ បាត់កូនអង្គុយចាំកូន ប្រហែលមួយម៉ោងក្រោយមកវាត្រឡប់មកវិញ វាថាវាទៅដើរលេង ។ កូនពៅនេះខ្លួនឱ្យវារៀន និងជួយលក់ដូងតិចតួច ខ្លួនពុំបានទទួលការអូសទាញឱ្យកូនទៅលក់ក្រមុំទេ ។ ចម្លើយខ្លួននៅនគរបាលដែលថា បានពឹងស្រីម្នាក់ឱ្យរកម៉ូយខុយក្រមុំស្រីពៅ ពុំពិតទេ ខ្លួនមិនដែលឆ្លើយបែបនេះទេ ។ ខ្លួនពុំបានណាត់ជួបភ្ញៀវនៅហាងកាហ្វេមណ្ឌលគីរីណាទេ ។ ខ្លួនពិតជាជំពាក់បំណុលអេស៊ីលីដាមែន ។ គ្មាននរណាធ្លាប់មកនិយាយពីរឿងខុយក្រមុំជាមួយខ្លួនទេ ។ ទៅដល់កន្លែងនគរបាលពុំបានឃើញជនជាប់ចោទ ៤នាក់នេះទេ ហើយក៏ពុំឃើញក្មេងពីរនាក់នេះនៅនគរបាលដែរ ។

-ជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយថា : ដំបូងម្ដាយខ្លួនឈឺ ពុំមានអង្ករហូប ខ្លួនក៏ចង់ឱ្យគេខុយក្រមុំយកលុយទៅ ដោយខ្លួនទៅជួយឈ្មោះ ចូវ រកម៉ូយឱ្យ ហើយឈ្មោះ ចូវ បាននាំខ្លួនទៅជួយឈ្មោះ ផាង បន្តទៀត ។ ខ្លួនបានកុហកម្ដាយថា ទៅធ្វើការហាងកាហ្វេ ។ ឈ្មោះ ចូវ ជាអ្នកនៅជិតផ្ទះម្ដាយខ្លួនដែរ ។ ម្ដាយខ្លួនមិនបានបង្ខំឱ្យលក់ខ្លួនទេ ។ កោសប្រហិតនៅផ្ទះឈ្មោះ ផាង ពុំមានប្រាក់ខែទេ ខ្លួនកោសប្រហិតឱ្យគាត់បាន ១ខែ ។ ខ្លួនបានសុំខ្ចីប្រាក់ពីឈ្មោះ ផាង ចំនួន ៤០ ដុល្លាមុន ហើយយកទៅឱ្យម្ដាយ និងប្រាប់ម្ដាយថា សុំខ្ចីលុយពីថៅកែមុនចូលឆ្នាំ ។ ឈ្មោះ ផាង ពិតជាទាក់ទងជាមួយឈ្មោះ ធី និងឈ្មោះ ពៅ នាំគ្នារកភ្ញៀវមកខុយក្រមុំខ្លួនមែន សំដីដែលអ្នកទាំងបីនាក់នេះឆ្លើយថា ពុំបានរកម៉ូយខុយក្រមុំខ្លួនពុំពិតទេ ពួកគាត់កុហក ។ ដំបូងពួកគាត់នាំខ្លួនទៅជួបនឹងភ្ញៀវជនជាតិខ្មែរនៅក្រុមហ៊ុនពុំស្គាល់នៅជាន់ខាងលើក្រុមហ៊ុននោះតែម្ដង ហើយភ្ញៀវនោះមើលទៅដូចជាអ្នកធ្វើការក្រុមហ៊ុន ។ ក្រោយមកទៀតឈ្មោះ ផាង បាននាំខ្លួនទៅហាងកាហ្វេនៅផ្សារសូរិយាទើបបានជួបនឹងឈ្មោះ ពៅ ហើយក៏បានជួបនឹងភ្ញៀវបីនាក់ទៀតផង ។ បន្ទាប់មកបីនាក់គាត់បាននាំខ្លួន និងឈ្មោះ ពៅ ទៅពេទ្យមើលឈាម និងមានពេទ្យស្រីពិនិត្យប្រដាប់ភេទខ្លួនទៀតផង ហើយឈ្មោះ ធី និងឈ្មោះ ពៅ ក៏នាំខ្លួន និងស្រីពៅ ទៅហាងបាយដោយឈ្មោះ ពៅ និងឈ្មោះ ធី បានឱ្យពួកខ្លួនទៅបន្ទប់ទឹកតែងខ្លួនលាបម្សៅ ក្រែម បាញ់ទឹកអប់ទៀតផង ។ ឯឈ្មោះ ផាង ត្រឡប់ទៅផ្ទះមុន ។ បន្ទាប់មកឈ្មោះ ពៅ និងឈ្មោះ ធី បាននាំខ្លួន និងស្រីពៅ ជិះអាតុតុ ទៅសណ្ឋាគារតែម្ដង ។ នៅសណ្ឋាគារបានឃើញភ្ញៀវហើយ ភ្ញៀវនោះអង្គុយឆ្ងាយមើលមកពួកខ្លួន តែខ្លួនពុំដឹងថាភ្ញៀវនោះជាជនជាតិអ្វីទេ ខ្លួនឃើញឈ្មោះ ធី និងឈ្មោះ ពៅ ទៅជួបភ្ញៀវនោះ ហើយឃើញភ្ញៀវនោះឱ្យលុយទៅឈ្មោះ ធី ខ្លួនគិតថា លុយនោះប្រហែល ១០០០ដុល្លា តែខ្លួនក៏ពុំបានឃើញលុយនោះច្បាស់ទេ ។ ឈ្មោះ ធី និងឈ្មោះ ពៅ ពុំបានឱ្យលុយនោះមកពួកខ្លួនទេ ។ ចំពោះចម្លើយខ្លួននៅនគរបាលដែលឆ្លើយថា ម្ដាយខ្លួនបាននាំខ្លួនទៅគឺពុំត្រឹមត្រូវទេខ្លួនសុំបដិសេធព្រោះពេលនោះខ្លួនភ័យពេកចេះតែនិយាយ និងថាតាមនគរបាលទៅ ។ ខ្លួនត្រូវបានពួកគាត់នាំទៅឱ្យភ្ញៀវមើលចំនួន ៥/

ផង ។ ថ្ងៃចុងក្រោយជិះអាធុក១ ទៅគ្នាបួននាក់គឺខ្លួន ឈ្មោះ ស្រីពៅ ឈ្មោះ ពៅ និងឈ្មោះ ធី ។ ពេលកំពុងអង្គុយចាំភ្ញៀវនៅជាន់ក្រោមក្នុងសណ្ឋាគារក៏ត្រូវនគរបាលមកតែម្តង ។ ការនាំទៅជួបភ្ញៀវ លើកទី១ ឆ្នាំ២០០៩ ឈ្មោះ ផាង នាំខ្លួនទៅ ។ លើកទី២ ឆ្នាំ២០០៩ ចូលឆ្នាំចិន ។ លើកទី៣ ពុំចាំឆ្នាំណាទេ ។ ខ្លួនបានចូលឱ្យពេទ្យពិនិត្យពីរដង ។

-ជនរងគ្រោះឈ្មោះ [redacted] ពៅ បានឆ្លើយថា : ដំបូងខ្លួនដើរលេងជិត១ ផ្សារថ្មី ហើយក៏ទូរស័ព្ទទៅឈ្មោះ [redacted] ធី សួរពីរឿងរកភ្ញៀវខុយក្រមុំខ្លួន ហើយគាត់បានហៅខ្លួនទៅហាងកាហ្វេមណ្ឌលគីរីឱ្យភ្ញៀវមើល ក្រោយពីខ្លួនទៅដល់ហើយមួយសន្ទុះធំទើបមានភ្ញៀវប្រុស១ ចូលមកខ្លួនឃើញខ្មែរពីរនាក់ និងជនជាតិចិនម្នាក់ ។ ខ្លួន និងភ្ញៀវអង្គុយតុផ្សេងគ្នាគឺរំលងផ្លូវដើរកណ្តាល បន្ទាប់មកឈ្មោះ [redacted] ធី និងឈ្មោះ ពៅ ប្រាប់ខ្លួន និងឈ្មោះ ម៉ាយ ថា ពួកហ្វែងទាំងពីរនាក់ភ្ញៀវត្រូវទាំងអស់ ហើយពួកគាត់បាននាំខ្លួន និងស្រីពៅ ជិះអាតុតុទៅផ្សារកណ្តាលផ្ទះពេទ្យមិនស្គាល់ឱ្យពេទ្យពិនិត្យក្រមុំពួកខ្លួន ដោយពេទ្យបានឱ្យខ្លួនស្រាតខោដើម្បីពិនិត្យ ហើយពេទ្យបានចេញក្រដាសបញ្ជាក់ថានៅក្រមុំទៀតផង ។ បន្ទាប់មកនាំទៅហូបបាយនៅហាងកាហ្វេយូអេនមី ហើយគាត់ឱ្យពួកខ្លួនទៅបន្ទប់ទឹកលាបម្សៅ ។ មេបានប្រាប់ខ្លួនថា ការលក់ក្រមុំគឺទៅដេកជាមួយភ្ញៀវកុំយំហើយកុំស្រែក ។ ខ្លួនបានទារថ្លៃលក់ក្រមុំចំនួន ១០០០ដុល្លា តែឈ្មោះ ពៅ និងឈ្មោះ ធី ថា បានត្រឹមតែ ៥០០ដុល្លាអីអស់ហើយ ។ ក្រោយពេលតែងខ្លួនហើយទៅឡាក់គីស្តាដោយជិះអាតុតុបួនាក់ ហើយចូលទៅអង្គុយចាំភ្ញៀវនៅខាងមុខជាន់ក្រោមកន្លែងអង្គុយពុំទាន់ឃើញភ្ញៀវទេ ក៏មាននគរបាលមកចាប់តែម្តង ។ ម្តាយខ្លួនឈ្មោះ [redacted] អេះ គាត់ពុំឱ្យខ្លួនទៅលក់ក្រមុំទេ គាត់ឱ្យទៅរៀន ខ្លួនសម្រេចចិត្តលក់ខ្លួនដោយខ្លួនឯងពុំមែនម្តាយបង្ខំទេ ហើយម្តាយខ្លួនក៏ពុំបាននាំខ្លួនទៅឱ្យគេខុយក្រមុំអីដែរ ខ្លួនលួចទៅដោយខ្លួនឯង ។ ដំបូងឈ្មោះ ធី និងឈ្មោះ ពៅ បានទិញដួងខ្លួននៅផ្សារថ្មីហើយក៏ទាក់ទងខ្លួនតែម្តង ខ្លួនយូរដួងលក់ផ្សេងពីម្តាយ ម្តាយខ្លួនពុំដឹងទេ ។ ពួកគាត់បានសួរខ្លួនថា ម្តាយខ្លួនមានជំពាក់លុយគេទេ ខ្លួនថា ជំពាក់ច្រើន ពួកគាត់ថា ក្មួយឯងត្រូវខំជួយរកលុយម្តាយ ហើយគាត់បានលៃនាំខ្លួនឱ្យទៅខុយក្រមុំតែម្តង ខ្លួនខ្មាចម្ចាស់បំណុលយកផ្ទះអត់មានអីនៅក៏ទៅលក់ខ្លួនយកប្រាក់សងគេវិញ ព្រោះនៅជំពាក់គេប្រហែល ១០០០ដុល្លាទៀត ។ ចម្លើយនៅនគរបាលថា ម្តាយនាំទៅគឺខ្លួនយំពេកពុំបានឆ្លើយបែបនោះទេ នគរបាលអានឱ្យស្តាប់ដែរ តែខ្លួនពុំបានស្តាប់ទេ គិតតែពីយំ ។ ពេលតែខ្លួនហើយជិះអាតុតុទាំងបួននាក់ហើយចូលសណ្ឋាគារក៏ទាំងបួននាក់ដែរ ។ ខ្លួនពុំចង់ឱ្យម្តាយខ្លួនជាប់គុកទេ ។ រយៈពេល ៨ខែដែលខ្លួននៅអង្គការ ខ្លួនយល់ថា នៅជាមួយម្តាយបានសុខជាងព្រោះមានភាពកក់ក្តៅជាង ។ ខាងអង្គការពុំបានបង្គាប់ឱ្យខ្លួននិយាយទេ ហើយក៏ពុំបានបង្ខំអីដែរ ខ្លួននិយាយតាមតែការពិត ។ ខ្លួនមានអាយុ ១៥ឆ្នាំ តែពុំដឹងថា ខ្លួនឯងកើតឆ្នាំអីទេ ។

-សាក្សីឈ្មោះ [redacted] បានឆ្លើយថា : ខ្លួនគ្រាន់តែដឹងថា ឈ្មោះ [redacted] ធី ជាអ្នករកស៊ីតូកដេរជី ក្រៅពីនេះពុំដឹងអ្វីទេ ហើយរឿងក្មេង១ នេះក៏ពុំដឹងដែរ



Scanned by CamScanner

-លោក [redacted] ជាមន្ត្រីនគរបាលបានឆ្លើយថា : ខ្លួនជាអនុប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ។ នៅថ្ងៃទី២២ ទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ការិយាល័យខ្លួនបានទទួលព័ត៌មានការមានការជួញដូរក្រមុំ ។ ដំបូងគ្រាន់តែដឹងថា ឈ្មោះ [redacted]ពៅ នេះជាអ្នកសង្ស័យ ក៏បានដាក់កំលាំងតាមរហូតឈានដល់ការបង្ក្រាបតែម្តង ។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ពេលព្រឹកកំលាំងខ្លួនបានដឹងថា ឈ្មោះ ពៅ និងឈ្មោះ ធី បាននាំក្មេង១ ទៅឱ្យពេទ្យពិនិត្យឈាម រួចទៅហូបបាយរហូតដល់ម៉ោង ១ឃើញទៅសណ្ឋាគារឡាក់គីស្តា កំលាំងខ្លួនក៏នៅតែពុំទាន់ធ្វើសកម្មភាពទេដោយរង់ចាំអ្នកទិញក្រមុំមក ។ ប្រហែលជា ១ម៉ោងក្រោយមកកំលាំងយើងសន្មត់ថា អ្នកទិញមកដល់ហើយក៏ធ្វើសកម្មភាពបង្ក្រាប ហើយធ្វើការឃាត់ខ្លួនបានឈ្មោះ ពៅ និងឈ្មោះ ធី រួមទាំងក្មេង១ ទាំងពីរនាក់នេះតែម្តង ។ ចំពោះរាល់ចម្លើយរបស់ជនទាំងនេះនៅនគរបាល ខាងខ្លួនបានអនុវត្តតាមនីតិវិធីត្រឹមត្រូវណាស់ទៅហើយ ។ ពេលសួរក្មេងក៏មានឪពុកម្តាយ ឬអាណាព្យាបាលចូលរួមដែរ ។ ខ្លួនសូមបញ្ជាក់ថា មនុស្សបីនាក់នេះខ្លួនពុំបានចុះទៅចាប់ទេ គឺកូនចៅខ្លួនជាអ្នកចុះទៅ ។ ក្នុងរឿងនេះ កំលាំងខ្លួនពុំអាចកំណត់មុខសញ្ញាជាអ្នកទិញបាននៅឡើយទេ ។ ចំពោះស្ត្រីពីរនាក់ដែលជាម្តាយនេះពុំមានវត្តមាននៅសណ្ឋាគារនោះទេ គឺកំលាំងយើងបានហៅគាត់មកសាកសួរហើយក៏បានឃាត់ខ្លួនគាត់តែម្តង ។ ឃាត់ឈ្មោះ ពៅ ឈ្មោះ ធី ឈ្មោះ ម៉ាយ និងឈ្មោះ ស្រីពៅ ហើយទើបឈានដល់ការឃាត់ខ្លួនឈ្មោះ ជាង ឈ្មោះ អេះ និងឈ្មោះ ហឿង នៅកន្លែងផ្សេង១ ពីគ្នា ។ ឈ្មោះ ពៅ ឆ្លើយថា ឃាត់ខ្លួនពុំអាចកំណត់មុខសញ្ញាជាអ្នកទិញបាននៅឡើយទេ ។ ចំពោះស្ត្រីពីរនាក់ដែលជាម្តាយនេះពុំមានវត្តមាននៅសណ្ឋាគារនោះទេ គឺកំលាំងយើងបានហៅគាត់មកសាកសួរហើយក៏បានឃាត់ខ្លួនគាត់តែម្តង ។ ឈ្មោះ ពៅ ឆ្លើយថា ឃាត់ខ្លួនគាត់ក្រោយគេពុំត្រឹមត្រូវទេ ។ ករណីនេះខ្លួនយល់ឃើញថា ជាករណីជាក់ស្តែងហើយ ខ្លួនក៏មានបំណងចង់ចាប់ទាំងភ្ញៀវដែរតែរកមិនឃើញ ។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុតាងលេខ ៩៩ អ.យ.ញ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០១០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-លោក [redacted] មេធាវីការពារជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋានការពារថា : តាមសំដីរបស់ជនជាប់ចោទទាំងប្រាំនាក់នេះ ខ្លួនយល់ឃើញថា ក្នុងរឿងនេះពុំមែនជាអំពើអនាចារ ពេស្យាចារលើអនីតិជនទេ តែជាបទល្មើស សញ្ចារកម្ម តាមមាត្រា ២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ឈ្មោះ [redacted]ហឿង បានដឹងពីការលក់ក្រមុំរបស់កូនគាត់យ៉ាងច្បាស់ ហើយឈ្មោះ [redacted]ជាង ជាអ្នកចិញ្ចឹមស្រី១ ជាច្រើនទៀតផង ជាក់ស្តែងឃើញនៅក្នុងសំណុំរឿងមានចម្លើយដែលបញ្ជាក់ថា មានឈ្មោះ លីន ឬឈ្មោះ ដា ជាអ្នកបានឱបកូនក្តីខ្លួនទៅឱ្យជួបភ្ញៀវរហូតទៅដល់ពីរដងឯណោះ ។ ឈ្មោះ [redacted]ជាង បាននាំកូនក្តីខ្លួនឱ្យទៅជួបឈ្មោះ [redacted] ពៅ និងឈ្មោះ [redacted]ធី នេះបញ្ជាក់ថា ឈ្មោះ [redacted] ជាង បានអូសទាញកូនក្តីខ្លួនឱ្យទៅលក់ក្រមុំ និងថែមទាំងបានរក្សាទុកកូនក្តីខ្លួនដែលជាអនីតិជនទៅទៀត ។ ឈ្មោះ [redacted] អេះ ក៏បានដឹងពីរឿងដែល



Scanned by CamScanner

ឈ្មោះ [redacted]ពៅ ទៅយកក្រមុំវៃវ ។ ឈ្មោះ [redacted] ពៅ និងឈ្មោះ [redacted]ធី មានជំនាញខាងលក់ក្រមុំ ហើយបានលួងលោមកូនក្ដីខ្លួនថា ឱ្យជួយរកលុយដោះបំណុលម្ដាយ និងបានជូនកូនក្ដីខ្លួនទាំងពីរនាក់ទៅពិនិត្យឈាមនៅគ្លីនិចចំរុង ។ ជនជាប់ចោទពិតជាមានគំរោងច្បាស់ណាស់ហើយពុំមែនទើបតែប្រព្រឹត្តជាលើកទីមួយនោះទេ ជាក់ស្ដែងករណីរបស់កូនក្ដីខ្លួននេះបើសមត្ថកិច្ចនគរបាលចុះទៅបង្ក្រាបពុំទាន់ពេលទេ កូនក្ដីទាំងពីរនាក់ប្រាកដជាត្រូវបានគេខុយក្រមុំបាត់ទៅហើយ ។ សុំឱ្យផ្ដន្ទាទោសជនល្មើសពីបទ សញ្ចារកម្ម តាមមាត្រា ២៨ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ សុំឱ្យតុលាការសម្រេចសំណង និងជម្ងឺចិត្តដល់កូនក្ដីខ្លួនឈ្មោះ [redacted]ពៅ ចំនួន ៥០០០ដុល្លា ។ សូមតុលាការផ្ដន្ទាទោសជនជាប់ចោទទាំងប្រាំនាក់នេះតាមច្បាប់ ។

**-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា :** ឆ្លងតាមការពិនិត្យសំណុំរឿង និងក្រោយពីបានស្ដាប់ការសួរដេញដោលនាពេលសវនាការនេះរួចមកឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] ពៅ ឈ្មោះ [redacted]ធី ឈ្មោះ [redacted] ផាង ឈ្មោះ [redacted] អេះ និងឈ្មោះ[redacted]ហ៊្សឿង និងជនរងគ្រោះឈ្មោះ [redacted]ពៅ និងឈ្មោះ [redacted]ម៉ាយ បញ្ជាក់ថា ជនជាប់ចោទទាំងប្រាំនាក់ពិតជាបានរួមគំនិតគ្នារកម៉ូយមកទិញក្រមុំជនរងគ្រោះទាំងពីរនាក់មែន ។ អំពើរបស់ជនជាប់ចោទទាំងប្រាំនាក់នេះជាបទល្មើស អូសទាញពេស្យាចារកុមារ ដែលមានចែងក្នុងមាត្រា ៣៥ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ សូមតម្កល់ការចោទប្រកាន់ទាំងស្រុងដូចក្នុងដីកាសន្និដ្ឋានស្ថាពរទាំងស្រុង ។

**-លោក [redacted]សុត្ថា មេធាវីការពារជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានការពារថា :** សុំតម្កល់ចម្លើយរបស់ឈ្មោះ [redacted] ផាង និងឈ្មោះ [redacted]ហ៊្សឿង នៅចំពោះមុខអយ្យការ និងនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ឈ្មោះ [redacted] ផាង គ្រាន់តែបានឱ្យឈ្មោះ[redacted]ម៉ាយ កោសប្រហិតប៉ុណ្ណោះ ។ ការឃាត់ខ្លួនកូនក្ដីខ្លួន និងជនជាប់ចោទផ្សេងទៀត ត្រូវបានសមត្ថកិច្ចនគរបាលឆ្លើយបំភ្លឺជូនតុលាការថា នេះជាករណីបទល្មើសជាក់ស្ដែង តែតាមពិតវាពុំមែនជាករណីជាក់ស្ដែងទេ ព្រោះថាកូនក្ដីខ្លួនឈ្មោះ [redacted]ផាង កំពុងនៅផ្ទះហូបបាយក៏ត្រូវបានគេកុហកថា កូនគាត់គ្រោះថ្នាក់ចរាចរហៅគាត់ទៅមើល ពេលគាត់ទៅតាមក៏ឱបគាត់ទៅកន្លែងនគរបាលតែម្ដង នេះគឺជាកំហុសនីតិវិធីទាំងស្រុងទៅហើយ ។ តាមចម្លើយឈ្មោះ [redacted]ពៅ ឈ្មោះ [redacted] ធី បញ្ជាក់ថា ការឃាត់ខ្លួនពួកគាត់គឺធ្វើឡើងនៅខាងក្រៅសណ្ឋាគារ ឯនគរបាលបែរជាអះអាងថា នៅក្នុងសណ្ឋាគារទៅវិញ ។ កូនក្ដីខ្លួនឈ្មោះ [redacted] ផាង ពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ទេ ព្រោះគាត់គ្រាន់តែឱ្យឈ្មោះ[redacted]ម៉ាយ បម្រើការងារផ្ទះ ហើយកោសប្រហិតដែលទទួលបានប្រាក់ខែ ៤០ដុល្លាទៀតផង ។ ចម្លើយរបស់ជនរងគ្រោះនៅដំណាក់កាលនគរបាលធ្វើឡើងដោយពុំបានត្រឹមត្រូវតាមនីតិវិធីទេ ព្រោះជនរងគ្រោះជាអនីតិជន ហើយនគរបាលយកចម្លើយដោយគ្មានឪពុកម្ដាយ ឬអាណាព្យាបាលបានចូលរួមនោះទេ ខ្លួនសុំធ្វើការបដិសេធចម្លើយនេះទាំងស្រុង ។ ជនរងគ្រោះឈ្មោះ [redacted]ម៉ាយ បានឆ្លើយតាំងពីដំណាក់



Scanned by CamScanner

កាលនគរបាលរហូតមកដល់ពេលសវនាការនេះគាត់យកពាក្យថា កុហកមកនិយាយរហូត ។ សំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់លើឈ្មោះ[redacted]ផាង ។

**-លោក [redacted]ក្លា មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា :**
ឈ្មោះ [redacted] ផាង បានឆ្លើយបញ្ជាក់ជូនតុលាការហើយថា គាត់បានទទួលយកឈ្មោះ [redacted]ម៉ាយ ពីម្តាយឈ្មោះ [redacted]ហឿង ដើម្បីឱ្យកោសប្រហិតប៉ុណ្ណោះ ឈ្មោះ[redacted]ហឿង មិនបានទាក់ទងឱ្យគេខុយក្រមុំកូនគាត់ឡើយ ។ តាមចម្លើយរបស់ឈ្មោះ[redacted] ពៅ និងឈ្មោះ [redacted]ធី ក៏បានបញ្ជាក់យ៉ាងច្បាស់ថា ពុំបានស្គាល់ឈ្មោះ [redacted]អេះ និងឈ្មោះ [redacted]ហឿង ឡើយ ។ ជនរងគ្រោះទាំងពីរនាក់ក៏បានអះអាងថា ម្តាយរបស់ពួកគេពុំបានដឹងពីរឿងខុយក្រមុំទេ គឺពួកគាត់បានសម្រេចចិត្តធ្វើការលក់ក្រមុំដោយខ្លួនឯង និងពុំប្រាប់ម្តាយទេ ហើយថែមទាំងកុហកម្តាយទៀត ដោយឈ្មោះ [redacted]ម៉ាយ កុហកថា ទៅរត់តុហាងកាហ្វេ ឯឈ្មោះ[redacted] ពៅ កុហកថា ទៅដើរលេងជិត១ នោះមួយភ្លែត ។ សុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] អេះ និងឈ្មោះ [redacted]ហឿង រួចផុតពីបទចោទប្រកាន់ ។

**-លោក [redacted]ហាល់ មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា :**
ឈ្មោះ [redacted] ធី បានបញ្ជាក់ជូនអង្គសវនាការហើយថា ពុំបានស្គាល់ជនរងគ្រោះទេ ។ កូនក្តីខ្លួនឈ្មោះ [redacted]ធី បានទៅម៉ុំឡាក់គីស្តាដើម្បីទំនាក់ទំនងការងាររកស៊ីតូកជេរជី និងផ្ទះ ហើយត្រូវបាននគរបាលឃាត់ខ្លួន ហើយនគរបាលបានអះអាងថា កូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសជាក់ស្តែងទៅវិញ នេះពុំមែនជាបទល្មើសជាក់ស្តែងទេ គ្មានទេ ។ កូនក្តីខ្លួនបានឆ្លើយបញ្ជាក់ហើយថា នៅកន្លែងនគរបាលបានឃើញតែឈ្មោះ [redacted]ពៅ ស្រាប់បាត់ទៅហើយ ។ សូមតុលាការពិចារណាពីចម្លើយកូនក្តីខ្លួននៅដំណាក់កាលនគរបាលដោយហេតុថា ចម្លើយនោះកើតឡើងដោយមានការបង្ខិតបង្ខំ ។ សំណូមពរសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។

**-លោក [redacted] សម្បត្តិ មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា :**
ក្នុងរឿងនេះនគរបាលគ្រាន់តែបានឃាត់ខ្លួនកូនក្តីខ្លួននៅខាងមុខសណ្ឋាគារ ពុំមែននៅក្នុងសណ្ឋាគារនោះទេហើយការចាប់ខ្លួនកូនក្តីខ្លួនធ្វើឡើងដោយពុំត្រឹមត្រូវដែរ ព្រោះគ្មានដីកាចាប់ខ្លួនផង ហើយនេះពុំមែនជាបទល្មើសជាក់ស្តែងនោះទេ ។ នគរបាលបានឃាត់ខ្លួនកូនក្តីខ្លួននៅពេលដែលគាត់កំពុងតែដើររកស៊ីតូកជេរជី និងផ្ទះ ពុំមែនកំពុងប្រព្រឹត្តបទល្មើសណាមួយនោះទេ បើនគរបាលថា មានការលក់ក្រមុំក្មេងហេតុអីមិនចាប់ទាំងអ្នកទិញផង ក្នុងរឿងនេះឃើញថា ពុំឃើញមានអ្នកទិញផងទៅ ។ ខ្លួនសុំឱ្យតុលាការបដិសេធចម្លើយនៅដំណាក់កាលនគរបាលចោលទាំងស្រុង ។ សំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់ដល់កូនក្តីខ្លួន ។

-ជនជាប់ចោទឈ្មោះ[redacted]ពៅ ឈ្មោះ[redacted] ធី ឈ្មោះ [redacted]ហឿង ឈ្មោះ [redacted] ផាង និងឈ្មោះ [redacted]អេះ បាននិយាយសំដីចុងក្រោយថា : សុំឱ្យតុលាការជួយលើកលែងការចោទប្រកាន់ដល់ពួកខ្លួនផង ។



Scanned by CamScanner

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីបានស្តាប់អំណានឯកសារពាក់ព័ន្ធក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងត្រឹមត្រូវហើយ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌនេះមកជំនុំជម្រះពីបទ អូសទាញពេស្យាចារកុមារ ដោយមានជនជាប់ចោទចំនួន ៥រូប គឺឈ្មោះ [redacted]ផាង ឈ្មោះ [redacted]អេះ ឈ្មោះ [redacted]ធី ឈ្មោះ [redacted]ហឿង និងឈ្មោះ [redacted] ពៅ ។ អំពើអូសទាញពេស្យាចារកុមារ គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ថា "ជនណាអូសទាញជនដទៃសម្រាប់អំពើពេស្យាចារកុមារ ឬផ្សាយពាណិជ្ជកម្មនូវអំពើពេស្យាចារកុមារ ក្នុងគោលដៅធ្វើជាអន្តរការីនៃអំពើពេស្យាចារកុមារនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ដល់ ១០ ០០០ ០០០ (ដប់លាន) រៀល ។ ជនណាប្រព្រឹត្តបទល្មើសខាងលើធ្វើជាមុខរបរត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ" ។

-នាពេលសវនាការជនជាប់ចោទឈ្មោះ[redacted]ផាង បានឆ្លើយថា ខ្លួនពុំស្គាល់ឈ្មោះ ចូវ និងពុំបានលក់ឈ្មោះ [redacted]ម៉ាយ ទេ ហើយកាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ខ្លួនក៏ពុំបាននាំឈ្មោះ [redacted]ម៉ាយ ទៅណាដែរ គឺនៅថ្ងៃនោះខ្លួនទៅផ្សារតាំងពីម៉ោង ៥ព្រឹក រហូតដល់ម៉ោង ១២ថ្ងៃត្រង់ ។ ប៉ុន្តែតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted]ម៉ាយ នាពេលសវនាការបានឆ្លើយបញ្ជាក់ថា ខ្លួនចង់ឱ្យគេខុយក្រមុំរបស់ខ្លួនដើម្បីយកលុយ ហើយខ្លួនក៏ទៅជួបឈ្មោះ ចូវ ឱ្យរកម្ញ៉យ បន្ទាប់មកឈ្មោះ ចូវ បាននាំខ្លួនទៅជួបឈ្មោះ [redacted] ផាង ដោយឈ្មោះនេះបានធ្វើការទំនាក់ទំនងជាមួយឈ្មោះ[redacted] ធី និងឈ្មោះ[redacted] ពៅ ដើម្បីនាំខ្លួនទៅរកភ្ញៀវខុយក្រមុំ ។ ហេតុនេះ ការពោលអះអាងរបស់ជនជាប់ចោទដែលថា ខ្លួនពុំស្គាល់ឈ្មោះ ចូវ និងពុំបាននាំជនរងគ្រោះទៅលក់ព្រហ្មចារី ពុំអាចឱ្យតុលាការជឿបានឡើយ ។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted]ម៉ាយ ក៏ដូចជា ចម្លើយរបស់ជនរង



Scanned by CamScanner

គ្រោះឈ្មោះ [redacted] ពៅ មានលក្ខណៈស្របគ្នាដែលបានបញ្ជាក់ថា ឈ្មោះ [redacted]ធី និង ឈ្មោះ [redacted]ពៅ ពិតជាបាននាំពួកខ្លួនទៅរកភ្ញៀវដើម្បីលក់ព្រហ្មចារីមែន ដោយអ្នកទាំងពីរនេះបាននាំពួកខ្លួនទៅឱ្យភ្ញៀវមើល និងបាននាំទៅមើលឈាម និងពិនិត្យប្រដាប់ភេទនៅមន្ទីរពេទ្យ ហើយបាននាំពួកខ្លួនទៅតុបតែងខ្លួន បន្ទាប់មកក៏ជិះអាចុក១ ទៅសណ្ឋាគារឡាក់គីស្តាដើម្បីជួបភ្ញៀវ ។ ចម្លើយនេះឃើញថា មានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយរបស់ឈ្មោះ[redacted]ដែលជាមន្ត្រីនគរបាលយុត្តិធម៌ក៏បានបញ្ជាក់ផងដែរថា កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ តាមរយៈកំលាំងសម្ងាត់របស់ខ្លួនបានដឹងថា ឈ្មោះ [redacted] ពៅ និងឈ្មោះ [redacted] ធី បាននាំក្មេង១ ទៅពិនិត្យឈាម និងទៅសណ្ឋាគារឡាក់គីស្តា ដើម្បីលក់ក្រមុំក្មេង១ នោះឱ្យភ្ញៀវ ។ ហេតុនេះ ចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]ធី និងឈ្មោះ [redacted]ពៅ នាពេលសវនាការដែលបានឆ្លើយបដិសេធថា ពួកខ្លួនមិនបាននាំជនរងគ្រោះទាំងពីរនាក់ទៅពិនិត្យឈាម ដើម្បីលក់ព្រហ្មចារីនោះទេ នេះគឺគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ ពុំអាចឱ្យតុលាការជឿបានឡើយ ។

-ជនជាប់ចោទឈ្មោះ [redacted]ហ្មៀង បានឆ្លើយនាពេលសវនាការថា ខ្លួនពុំបានទាក់ទងជាមួយឈ្មោះ[redacted]ផាង ដើម្បីលក់ព្រហ្មចារីកូនទេ គឺខ្លួនគ្រាន់តែឱ្យកូនទៅនៅជាមួយឈ្មោះ [redacted] ផាង នេះ ដើម្បីស៊ីឈ្នួលកោសប្រហិតប៉ុណ្ណោះ ដោយទទួលបានប្រាក់ខែ ៤០ដុល្លាក្នុងមួយខែ ។ ផ្ទុយទៅវិញ ជនជាប់ចោទឈ្មោះ[redacted]ហ្មៀង មានផ្ទះនៅជិតនឹងផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] ផាង ហេតុនេះការឆ្លើយបដិសេធរបស់ជនជាប់ចោទដែលថា ខ្លួនពុំបានដឹងឮ និងពុំបានជាប់ទាក់ទងពីការលក់ក្រមុំព្រហ្មចារីរបស់កូនខ្លួន គឺពុំសមហេតុផលឡើយ ។ យ៉ាងណាមិញ ជនរងគ្រោះឈ្មោះ [redacted]ម៉ាយ បានឆ្លើយបដិសេធថា ម្តាយរបស់ខ្លួនពុំបានដឹងរឿងលក់ព្រហ្មចារីនោះទេ ។ ប៉ុន្តែចម្លើយបដិសេធនាពេលសវនាការនេះ គឺគ្រាន់តែជាចម្លើយដោះសារដើម្បីឱ្យម្តាយរបស់ខ្លួនរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ ។

-ជនជាប់ចោទឈ្មោះ [redacted] អេះ បានឆ្លើយនាពេលសវនាការថា ខ្លួនពុំបានយកកូនទៅលក់ឱ្យគេ ឬលក់ក្រមុំកូនឱ្យគេទេ ហើយខ្លួនក៏ដឹងពីរឿងខូចក្រមុំកូនទេ ប៉ុន្តែតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ពៅ នៅចំពោះមុខមន្ត្រីនគរបាលយ៉ាងច្បាស់លាស់ថា ម្តាយខ្លួនបាននាំខ្លួនទៅជួបឈ្មោះ[redacted]ពៅ និងឈ្មោះ[redacted]ធី ដែរ ដោយគាត់នៅចាំខ្លួនក្បែរហាងកាហ្វេមណ្ឌលគិរី ។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ផាង ឈ្មោះ [redacted] ធី និងឈ្មោះ [redacted]ពៅ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ នៅរាជធានីភ្នំពេញ ដែលបានបញ្ចុះបញ្ចូល និងនាំជនរងគ្រោះទៅលក់ក្រមុំព្រហ្មចារី ធ្វើឡើងច្រើនដងគឺជាអំពើដែលល្មើសទៅនឹងបញ្ញត្តិមាត្រា ៣៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ យ៉ាងណាមិញ អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ[redacted]ហ្មៀង និងឈ្មោះ[redacted]អេះ ដែលបានលួងលោម និងបញ្ចុះបញ្ចូល





Scanned by CamScanner

ក្មួនស្រីខ្លួនឱ្យលក់ក្រមុំព្រហ្មចារី គឺជាអំពើល្មើសទៅនឹងបញ្ញត្តិមាត្រា ៣៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-ជនជាប់ចោទឈ្មោះ [redacted]ពៅ ឈ្មោះ [redacted]ធី ឈ្មោះ [redacted]ជាង ឈ្មោះ [redacted]ហឿង និងឈ្មោះ [redacted]អេះ មានសមត្ថភាពគ្រប់គ្រាន់យល់ដឹងខុសត្រូវ អំពីអំពើប្រព្រឹត្តរបស់ខ្លួនអាចឱ្យទទួលខុសត្រូវព្រហ្មទណ្ឌបាន ។

-មានភស្តុតាងដាក់បន្ទុក និងមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]ពៅ ឈ្មោះ [redacted] ធី ឈ្មោះ [redacted]ជាង ឈ្មោះ [redacted]ហឿង និងឈ្មោះ [redacted]អេះ ពីបទ អូសទាញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-អំពើល្មើសរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ព្រមទាំងប្រពៃណីទំនៀមទំលាប់ដ៏ល្អរបស់ប្រជាពលរដ្ឋដែលច្បាប់កំណត់ជា បទល្មើសតម្រូវឱ្យផ្តន្ទាទោស ។

-សេចក្តីសន្និដ្ឋានរបស់លោក [redacted]ត្រា លោក [redacted] សម្បត្តិ ឈ្មោះ [redacted]ហាល និងឈ្មោះ [redacted]សុត្ថា ដែលស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ពុំអាចឱ្យតុលាការទទួលស្គាល់បានទេ ព្រោះថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទទាំងប្រាំនាក់នេះរួចទៅហើយ ។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោក [redacted]រឿន មេធាវីការពារជនរងគ្រោះដែលបានស្នើសុំឱ្យតុលាការកែប្រែបទចោទប្រកាន់ពីបទ អូសទាញពេស្យាចារកុមារ ទៅជាបទ សញ្ចារកម្ម ពុំមានភស្តុតាងគ្រប់គ្រាន់អាចឱ្យតុលាការទទួលស្គាល់បានទេ ពីព្រោះតាមអង្គហេតុក្នុងរឿងក្តីនេះមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើស អូសទាញពេស្យាចារកុមារ ប៉ុណ្ណោះ ។

-ជនជាប់ចោទឈ្មោះ[redacted]ហឿង និងឈ្មោះ [redacted] អេះ មានជីវភាពក្រីក្រ និងមានជម្ងឺដែលជាមូលហេតុនាំឱ្យដាច់ចិត្តអូសទាញកូនស្រីរបស់ខ្លួនឱ្យធ្វើពេស្យា ។

-ការទាមទាររបស់លោក [redacted]សារឿន ជាមេធាវីការពារជនរងគ្រោះឈ្មោះ [redacted] ពៅ ដែលទាមទារប្រាក់សំណងចំនួន ៥ 000 ដុល្លាអាមេរិក ពីឈ្មោះ [redacted] ធី និងឈ្មោះ[redacted] ពៅ ពុំមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ឡើយ ។ ហេតុនេះ តុលាការត្រូវលើកចោលការទាមទារនេះ ។

-ទូរស័ព្ទដៃម៉ាកណូគាចំនួន ៣គ្រឿង ដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ០៩៥ អ.យ.ញ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ គឺជាទូរស័ព្ទដែលជនជាប់ចោទប្រើប្រាស់ជាមធ្យោបាយដើម្បីទំនាក់ទំនងភ្ញៀវលក់ព្រហ្មចារីជនរងគ្រោះ ។ ហេតុនេះ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។ មួយវិញទៀត សៀវភៅកត់លេខទូរស័ព្ទចំនួន ៣ក្បាល ដូចក្នុងកំណត់ហេតុខាងលើ ក៏ជាមធ្យោបាយដែលជនជាប់ចោទប្រើប្រាស់ក្នុងការកត់ត្រាលេខទូរស័ព្ទភ្ញៀវក្នុងទំនាក់ទំនងទិញលក់ព្រហ្មចារី ដូច្នេះត្រូវរឹបអូសបំផ្លាញចោលដែរ



Scanned by CamScanner

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោស :

ក-ឈ្មោះ [redacted]ដាង ភេទ ស្រី អាយុ ៤០ឆ្នាំ ជាតិ ខ្មែរ

ខ-ឈ្មោះ [redacted]ធី ភេទ ស្រី អាយុ ៤៣ឆ្នាំ ជាតិ ខ្មែរ

គ-ឈ្មោះ [redacted]ពៅ ភេទ ស្រី អាយុ ៥១ឆ្នាំ ជាតិ ខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល **៧ឆ្នាំ ( ប្រាំពីរឆ្នាំ)**

ឃ-ឈ្មោះ [redacted]ហឿង ភេទ ស្រី អាយុ ៤៨ឆ្នាំ ជាតិ ខ្មែរ

ង-ឈ្មោះ [redacted]អេះ ភេទ ស្រី អាយុ ៥៩ឆ្នាំ ជាតិ ខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល **៣ឆ្នាំ** (**បីឆ្នាំ**) និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន ៤ ០០០ ០០០ រៀល (បួនលានរៀល)

ពីបទ **អូសទាញពេស្យាចារកុមារ** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១០ តាមមាត្រា ៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

២-លើកចោលការទាមទាររបស់មេធាវី **[redacted]សារឿន** របស់ជនរងគ្រោះឈ្មោះ សឹង ពៅ ។

៣-វត្ថុតាង :

ក-ទូរស័ព្ទដៃម៉ាកណូគាចំនួន ៣គ្រឿង ដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ០៩៩ អ.យ.ញ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

ខ-សៀវភៅកត់លេខទូរស័ព្ទចំនួន ៣ក្បាល ត្រូវរឹបអូសបំផ្លាញចោល ។

៤-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ជនរងគ្រោះ មេធាវីការពារជនរងគ្រោះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ជនរងគ្រោះ មេធាវីការពារជនរងគ្រោះ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ធ្វើនៅ រាជធានីភ្នំពេញ . ថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១

**ក្រឡាបញ្ជី**

[redacted]